# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្ងាសនៅចំការទៀង
# ថ្ងៃទី២៥ មិថុនា ២០១៧

អត្ថបទទី១៖ យរ ២០,១០-១៣
អត្ថបទទី២៖ រម ៥,១២-១៥
ដំណឹងល្អ៖ មថ ១០,២៦-៣៣

បងប្អូនជាទីស្រឡាញ់!

ប៉ុន្មានថ្ងៃមុន ខ្ញុំបានរៀបចំឯកសារផ្ញើទៅទីក្រុងរ៉ូមអំពីចំនួនគ្រីស្តបរិស័ទនៅក្នុងភូមិភាគភ្នំពេញ ឃើញថាចំនួនគ្រីស្តបរិស័ទធ្លាក់ចុះពី១៥,០០០នាក់ មកត្រឹម ១២,០០០នាក់។ ប៉ុន្តែចំនួនប្រជាជនឡើងជាលំដាប់ សម្រាប់ប្រាំបីរាជធានី-ខេត្ត មាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ មានប្រជាជនប្រហែល ៦,១០០,០០០នាក់។ ក្នុងខេត្តតាកែវ យើងមានប្រជាជនប្រហែល ៨០០,០០០នាក់ និងមានគ្រីស្តបរិស័ទជាង៤០០នាក់ ប៉ុន្តែគេមិនបានស្នាក់នៅលើទឹកដីខេត្តតាកែវទាំងអស់ទេ មានខ្លះនៅភ្នំពេញ និងមានខ្លះទៀតនៅតាខេត្តផ្សេងៗ។ សម្រាប់បងប្អូនដែលនៅទីនេះថ្ងៃនេះ នៅក្នុងចំណោមប្រជាជនជាង៨០០,០០០នាក់ យើងជាគ្រីស្តបរិស័ទមួយចំនួនតូចដែលទទួលខុសត្រូវជាន់ខ្ពស់។ យើងមានគ្នាតិច ហេតុនេះហើយយើងត្រូវទទួលខុសត្រូវយ៉ាងខ្ពស់បំផុត។ ព្រះយេស៊ូមានព្រះបន្ទូលថា "**នៅពេលយើងសាបព្រោះតិច យើងច្រូតតិច នៅពេលយើងសាបព្រោះច្រើន យើងច្រូតច្រើន**" នៅក្នុងខេត្តតាកែវ យើងបានសាបព្រោះច្រើនដែរ។ បងប្អូនដែលជាគ្រីស្តបរិស័ទ បងប្អូនដែលនឹងទទួលអគ្គសញ្ញាលាបថ្ងាសថ្ងៃនេះ បានទទួលខុសត្រូវមួយយ៉ាងសំខាន់បំផុត គឺធ្វើដូចម្តេចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ អាចឲ្យមនុស្សទាំងអស់នៅក្នុងខេត្តតាកែវស្តាប់លឺ។

ព្រះជាម្ចាស់បានបងប្អូនមនុស្ស ជាបុរស ជាស្ត្រី ដើម្បីឲ្យប្រកាសដំណឹងល្អតាមរបៀបព្រះយេស៊ូ ពេលព្រះយេស៊ូចេញពីភូមិណាសារ៉ែតចូលស្រុកកាលីឡេ ព្រះអង្គមានព្រះបន្ទូលថា "**ព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ ចូរកែប្រែចិត្តគំនិត ហើយជឿលើដំណឹងល្អទៅ**" នេះជាអ្វីដែលយើងត្រូវការទទួលសម្រាប់ជីវិតយើង។ សម្រាប់បងប្អូនដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាពិសេសបងប្អូនទាំង៤៦នាក់ដែលទទួលអគ្គសញ្ញាលាបថ្ងាសថ្ងៃនេះ ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាកម្លាំងរបស់ព្រះជាម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានប្រាជ្ញាឈ្លៀសវៃ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើង

ចេះពិចារណាដឹងខុសដឹងត្រូវ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងដឹងសេចក្តីពិត ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានយោបល់ល្អ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានសេចក្តីអង់អាច ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងធ្វើតាមព្រះវិញ្ញាណតែម្តង និងព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងចេះគោរពកោតខ្លាចព្រះជាម្ចាស់ជានិច្ច។ នេះជាព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងទទួល ដើម្បីណែនាំឲ្យយើងចូលនៅក្នុងគម្រោងការដ៏ពិសេសរបស់ព្រះជាម្ចាស់ ដែលបានចាត់ព្រះយេស៊ូយាងមកដើម្បីប្រកាសអំពីដំណឹងល្អជូនដល់អ្នកក្រីក្រ។ ណែនាំឲ្យមនុស្សខ្វាក់មើលឃើញ មនុស្សពិការជើងដើរបាន អ្នកជំងឺបានជាសះស្បើយ នេះជាបេសកកម្មដែលយើងទទួល។

នៅឆ្នាំ២០០២ ព្រះសហគមន៍នេះយើងមានតែលោកគ្រូជៀងម្នាក់ ជាមួយក្រុមយុវជនតិចតួច ប៉ុន្តែសព្វថ្ងៃព្រះសហគមន៍របស់យើងមានជីវិត ដោយសារទីមួយព្រះជាម្ចាស់ដែលបានធ្វើការច្រើន និងទីពីរដោយសារបងប្អូនដែលបានស្តាប់លឺ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងសុខចិត្តដើរតាមព្រះជាម្ចាស់ ដើម្បីចែករំលែកធម៌មេត្តាករុណា តាមរយៈការអប់រំតាមសាលា តាមសិប្បកម្ម តាមភូមិសុខសាន្ត តាមក្រុមមេត្តាករុណា នេះទាំងអស់ណែនាំឲ្យយើងបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់ ប្រកបដោយសេចក្តីស្រឡាញ់ ប្រកបដោយសេចក្តីសុខសាន្ត និងណែនាំឲ្យមនុស្សមួយចំនួនមានអំណរសប្បាយពិតមែន។ អំណរសប្បាយរបស់ព្រះគ្រីស្តជាអំណរសប្បាយយ៉ាងពិតប្រាកដ ដែលណែនាំឲ្យជីវិតរបស់យើងមានតម្លៃមានអត្ថន័យដោយសារយើងមានគោលដៅ ដោយយកចិត្តទុកដាក់ធ្វើជាគ្រីស្តបរិស័ទដែលមានលក្ខណៈដូចព្រះជាម្ចាស់។ ដោយសារព្រះជាម្ចាស់បានបង្កើតយើងជាបុរសជាស្ត្រី ជារូបដំណាងរបស់ព្រះអង្គផ្ទាល់ មានន័យថាពេលគេឃើញយើង គេឃើញព្រះជាម្ចាស់ដែរ។ ព្រះជាម្ចាស់មានលក្ខណៈតែមួយគត់ គឺជាសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ ហេតុនេះហើយពីថ្ងៃដែលយើងកើត យើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងមានគោលដៅតែមួយធ្វើដូចម្តេចដើម្បីការពារថែរក្សារូបដំណាងរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់យើងរៀងៗខ្លួនផ្ទាល់។ មានន័យថាដើម្បីឲ្យយើងទៅជាព្រះជាម្ចាស់តូចមួយលើផែនដីនេះ ដែលវាបានណែនាំឲ្យជីវិតរបស់យើងមានកម្លាំង។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលបងប្អូនទទួលថ្ងៃនេះ ជាកម្លាំងដើម្បីទៅមុខ ជាអគ្គសញ្ញាដែលណែនាំឲ្យយើងទទួលព្រះវិញ្ញាណរបស់ព្រះជាម្ចាស់

តែម្តង។ ដើម្បីឲ្យយើងបន្តបំពេញគោលដៅរបស់យើង គឺមានលក្ខណៈដូចព្រះជាម្ចាស់ ដោយសារព្រះជាម្ចាស់បានបង្កើតយើង មានរូបរាងដូចព្រះអង្គ។

ព្រះសហគមន៍របស់យើង ដែលចាប់ផ្តើមពីគ្រីស្តបរិស័ទម្នាក់អាចរីកចម្រើនដល់សព្វថ្ងៃនេះ ដោយសារយើងឃើញជាក់ស្តែងអំពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់ដែលបានកើតជារូបរាងពិតមែន។ នេះជាសេចក្តីសង្ឃឹម និងជាកម្លាំងរបស់យើង ដើម្បីបន្តរស់នៅពីមួយថ្ងៃទៅមួយថ្ងៃដោយឆ្លងការឧបសគ្គដែលមាននៅក្នុងជីវិតរបស់យើង ដោយដឹងថាព្រះជាម្ចាស់គង់នៅ។ ទោះបីយើងដើរក្នុងភាពងងឹត ទោះបីយើងដើរវង្វេងផ្លូវមួយរយៈយើងដឹងថានៅខាងមុខមានពន្លឺរបស់ព្រះជាម្ចាស់ ដែលណែនាំឲ្យជីវិតរបស់យើងរកឃើញអត្ថន័យ រកឃើញតម្លៃ និងជាពិសេសរកឃើញសេចក្តីសង្ឃឹមជានិច្ច។ គ្រីស្តបរិស័តជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម។ បងប្អូនដែលនឹងទទួលអគ្គសញ្ញាលាបថ្វាសថ្ងៃនេះ មានមួយចំនួនមិនសូវចូលព្រះវិហារប៉ុន្មានទេ ប៉ុន្តែថ្ងៃនេះខ្ញុំបានឃើញបងប្អូនអង្គុយថ្ងៃនេះខ្ញុំសប្បាយចិត្តណាស់ ដោយសារយើងបានទទួលកម្លាំងពីព្រះជាម្ចាស់ ដែលណែនាំឲ្យយើងចូលក្នុងព្រះវិហារជារៀងរាល់សប្តាហ៍ ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលចិញ្ចឹមជីវិតយើង ដូចយើងបានស្តាប់ថា "**ខ្ញុំជាអាហារដែលចុះពីស្ថានបរមសុខមក ដើម្បីណែនាំឲ្យបងប្អូនមានជីវិតអស់កាលជានិច្ច**"។ ចុលព្រះវិហាររាល់សប្តាហ៍ ដើម្បីទទួលព្រះកាយព្រះគ្រីស្តដែលចិញ្ចឹមជីវិតរបស់យើងពិតមែន ដូចយើងស្តាប់ "**ព្រះកាយព្រះគ្រីស្តណែនាំឲ្យយើងទៅជាផ្លុងតែមួយ គ្រួសារតែមួយ**"។ ដូច្នេះយើងទទួលបេសកកម្មពីរថ្ងៃនេះ គឺទីមួយយកចិត្តទុកដាក់ចូលព្រះវិហារជារៀងរាល់ថ្ងៃ ទីពីរ ធ្វើដូចម្តេចដើម្បីឲ្យបងប្អូនឯទៀតៗអាចស្តាប់ព្រះបន្ទូលតាមជីវិតរបស់យើង។ ទីមួយដើម្បីប្រកាសដំណឹងល្អ ឲ្យយើងអញ្ជើញបងប្អូនដែលភ្លេចចូលព្រះវិហារពីយូរមកហើយ និងទីពីរ ធ្វើដូចម្តេចដើម្បីណែនាំយុវជនយុវនារី បងប្អូន តាយាយឲ្យស្តាប់ព្រះបន្ទូលដែលជូនកាលណែនាំឲ្យយើងមានជីវិតថ្មី។

យើងធ្វើដូចម្តេច ដើម្បីឲ្យព្រះសហគមន៍របស់យើងបន្តមានជីវិត បន្តមានសេចក្តីសង្ឃឹម ថ្ងៃនេះបងប្អូនទាំង៤៦នាក់ជាសេចក្តីសង្ឃឹមមួយយ៉ាងពិសេស សម្រាប់យើងទាំងអស់គ្នា។ នៅតាមកន្លែងដែលយើងនៅ ឲ្យយើងទទួលស្គាល់ថាយើងជាមេនៅក្នុងម្សៅនៃជីវិត ទោះយើងជាមេតូចប៉ុន្តែជាមេដែលមានឥទ្ធិពលនៃសេចក្តីស្រឡាញ់។ ឲ្យយើងបន្ត

ប្រកាសដំណឹងល្អរួមជាមួយព្រះយេស៊ូដែលមានព្រះបន្ទូលថា **“ព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ ចូរកែប្រែចិត្តគំនិត ហើយជឿលើដំណឹងល្អទៅ”**។ អាម៉ែន។